**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ......០...២.០......សកបយ

ភ្នំពេញ.ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការស្នើសុំយកពលកម្មបរទេស មកធ្វើការយកប្រាក់ឈ្នួលនៅព្រះរាជាណាចក្រកម្ពុជា

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស-រកម-០៦៩៩-០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ-បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០២

### ស ម្រេ ច

ប្រការ ១: ប្រកាសនេះកំណត់នីតិវិធីនៃការស្នើសុំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួល នៅតាមសហគ្រាសគ្រឹះស្ថាននានា ដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា ជនបរទេស ដែលធ្វើការយកប្រាក់ឈ្នួល ក្នុងប្រការ១នេះ មិនរាប់បញ្ចូលផងទេ នូវអ្នក

ការទូត បុគ្គលិកអង្គការអន្តរជាតិ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អ្នកជំនាញការ ឬទីប្រឹក្សារាជរដ្ឋាភិបាល ឬ ក្រសួងនានា និងអ្នកវិនិយោគទុន ដែលស្ថិតនៅក្រោមលក្ខន្តិកៈអ្នកការទូត ច្បាប់វិនិយោគទុន និងអង្គការមនុស្សធម៌ ដែលមានអនុស្សរណៈជាមួយស្ថាប័នរាជរដ្ឋាភិបាល ។

ជនបរទេសទាំងឡាយ ដែលបានកំណត់ក្នុងប្រការ១នេះ និងម្ចាស់សហគ្រាសគ្រឹះស្ថាន ដែលប្រើជនបរទេសទាំងនេះ ត្រូវប្រតិបត្តិឱ្យបានត្រឹមត្រូវតាម មាត្រា ២១ និង មាត្រា ២៦១ ដល់មាត្រា ២៦៥ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២: ជនបរទេសទាំងឡាយ ដូចដែលកំណត់ក្នុងប្រការ១ខាងលើ ត្រូវមានប័ណ្ណការងារ និងសៀវភៅការងារ ដែលចេញឱ្យដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទើបអាចធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ។

ចាប់ពីពេលនេះតទៅ សហគ្រាស គ្រឹះស្ថាននានា ដែលស្ថិតក្រោមបទបញ្ញត្តិមាត្រា១ នៃច្បាប់ស្តីពីការងារ នៅពេលត្រូវការនាំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួល ត្រូវធ្វើសំណើជាលាយលក្ខអក្សរ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

សំណើនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី ចំនួន មុខជំនាញ បច្ចេកទេសនៃហត្ថពលកម្មបរទេស និងប្រភពដែលត្រូវស្នើសុំយកជនបរទេស ព្រមទាំងលក្ខខណ្ឌការងារដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងពិនិត្យអនុញ្ញាតិផងដែរចំពោះប្រភពបេក្ខជនទាំងឡាយ ដែលត្រូវបានផ្តល់ជូនដោយនិយោជក ។

ប្រការ ៣: ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងផ្តល់អាជ្ញាប័ណ្ណឱ្យក្រុមហ៊ុនឯកជនធ្វើជាទីភ្នាក់ងារនានា ទទួលបន្ទុកការងារនាំយកហត្ថពលកម្មបរទេស ចូលមកធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របទៅតាមសំណើនីមួយៗ ។

ទីភ្នាក់ងារនានារបស់កម្ពុជា សហការជាមួយទីភ្នាក់ងារនានានៃប្រទេសដើមរបស់ជនបរទេស ដើម្បីធ្វើការពិនិត្យមើលអត្តសញ្ញាណ គុណវុឌ្ឍិ និងឯកសារផ្លូវច្បាប់របស់ជនបរទេសម្នាក់ៗ ។ ផ្អែកទៅតាមលទ្ធផលនៃការពិនិត្យនោះ ក្រសួងសំរេចអនុញ្ញាតិឱ្យនាំយកជនបរទេសចូលមកធ្វើការ នៅក្នុងសហគ្រាសគ្រឹះស្ថាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របទៅតាមករណីនីមួយៗ ហើយចាត់ឱ្យក្រុមហ៊ុនជាទីភ្នាក់ងារនានា រៀបចំឱ្យជនបរទេសចុះ កិច្ចសន្យាការងារជាមួយនឹងនិយោជក ស្របទៅតាមលក្ខខណ្ឌការងារ ដែលបានព្រមព្រៀងគ្នារួចហើយ ។

ចំពោះប្រភពបេក្ខជនទាំងឡាយដែលត្រូវបានផ្តល់ជូនដោយនិយោជក និយោជកអាចធ្វើការទាក់ទងជាមួយទីភ្នាក់ងារនៅប្រទេសរបស់សាមីជនបរទេសដោយផ្ទាល់ ដើម្បីកំណត់អំពីលក្ខខណ្ឌការងារ ។ ក្នុងករណីនេះ ទីភ្នាក់ងារនានានៃប្រទេសដើមរបស់សាមីជនបរទេស ត្រូវចុះកិច្ចសន្យានៃសេវាមុខរបរ ជាមួយទីភ្នាក់ងារនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅមុនពេលដែលសាមីជនបរទេស ត្រូវបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

ទីភ្នាក់ងាររបស់ក្រសួងទទួលខុសត្រូវចំពោះមុខក្រសួង ក្នុងការធានាឱ្យបានថា ជនបរទេសដែល

ត្រូវបាននាំចូលមកធ្វើការនៅតាមសហគ្រាសគ្រឹះស្ថាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា លុះត្រាតែ:

-មានគុណវុឌ្ឍិគ្រប់គ្រាន់ ត្រូវទៅតាមសេចក្តីត្រូវការរបស់សហគ្រាសគ្រឹះស្ថាន

-មានឯកសារផ្លូវច្បាប់ត្រឹមត្រូវ ស្របទៅតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ

-ត្រូវបានទទួលការបណ្តុះបណ្តាលអំពីច្បាប់ ទំនៀមទម្លាប់ ប្រពៃណី ភាសាខ្មែរ ក្នុងរយៈពេលយ៉ាងតិច ៨សប្តាហ៍ មុនពេលចូលធ្វើការ ឬនៅពេលចាប់ផ្តើមធ្វើការដំបូង។

-ត្រូវបានជានាសិទ្ធិស្របច្បាប់ នៅពេលដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤ : ចំពោះជនបរទេស ដែលមកពីប្រទេសផ្សេងៗ នៅមិនទាន់មានក្រុមហ៊ុនឯកជនជាទីភ្នាក់ងារទទួលបន្ទុកនៅឡើយ ក្រសួងនឹងពិនិត្យ និងសំរេចលើសំណើសុំនាំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួលនៅព្រះរាជាណាចក្រកម្ពុជា របស់សហគ្រាសគ្រឹះស្ថាន ដោយផ្ទាល់។ ក្នុងករណីនេះ សហគ្រាសគ្រឹះស្ថានត្រូវចុះកិច្ចសន្យាជាមួយសាមីជនបរទេស និងត្រូវធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេសភ្លាម នៅពេលដែលជនបរទេសចូលមក ដល់ព្រះរាជាណាចក្រកម្ពុជា។ សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក (ចលនាបុគ្គលិកចូល) ក៏ត្រូវធ្វើឱ្យបានស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ប្រការ ៥: កិច្ចសន្យាការងាររបស់ជនបរទេស ក្នុងមួយលើកៗ មានរយៈពេលមិនលើសពី ២ឆ្នាំ ឡើយ។ កិច្ចសន្យាការងារអាចធ្វើជាភាសាបរទេសបាន តែត្រូវមានភាសាខ្មែររួមជាមួយផងដែរ។ កិច្ចសន្យាការងារត្រូវកំណត់ឱ្យបានច្បាស់អំពីលក្ខខណ្ឌការងារសំខាន់ៗ និងឱ្យបានស្របតាមច្បាប់ស្តីពីការងារ ។ បើចង់បន្តធ្វើការងារនៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសត្រូវមានការអនុញ្ញាតិឱ្យធ្វើការងារនៅកម្ពុជា ជាថ្មីម្តងទៀត។

ប្រការ ៦ : ពេលចូលមកធ្វើការយកប្រាក់ឈ្នួលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសម្នាក់ៗ ត្រូវ:

ក. ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រឹមត្រូវតាមច្បាប់

ខ. មានលិខិតឆ្លងដែនត្រឹមត្រូវ

គ. មានប័ណ្ណស្នាក់នៅត្រឹមត្រូវ

ឃ. មានសញ្ញាប័ត្រ ឬឯកសារណាមួយបញ្ជាក់ថា មានបច្ចេកទេសមុខជំនាញវិជ្ជាជីវៈសមស្រប ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ច របស់ប្រទេសសាមីជនបរទេស ឬប្រទេសណាមួយ

ង. មានវិញ្ញាបនប័ត្រ ឬលិខិតណាមួយបញ្ជាក់ថា សាមីជនបរទេស មានកាយសម្បទាសមស្របទៅនឹងមុខរបរដែលត្រូវធ្វើ និងមិនមានជំងឺឆ្លងណាមួយឡើយ ដែលត្រូវបានចេញឱ្យដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា ឬ ស្ថាប័នមានសមត្ថកិច្ច នៃប្រទេសដើមរបស់សាមីជនបរទេស ឬ ប្រទេសដែលសាមីជនបរទេសស្នាក់នៅ។

ប្រការ ៧: ចាប់ពីពេលនេះតទៅ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មិនអនុញ្ញាតិឱ្យសហគ្រាសគ្រឹះស្ថាននានា នាំយកជនបរទេសចូលមកធ្វើការយកប្រាក់ឈ្នួលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតិពីក្រសួងជាមុនឡើយ។

ចំពោះជនបរទេសដែលបានចូលមកធ្វើការរួចហើយ មុនពេលចេញប្រកាសនេះ តែនៅមិនទាន់មានប័ណ្ណការងារ និងសៀវភៅការងារ ត្រូវរៀបចំបែបបទស្នើសុំប័ណ្ណការងារ និងសៀវភៅការងារឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ ២០០២។

ចំពោះសហគ្រាសគ្រឹះស្ថាន ដែលបានទទួលយកជនបរទេសឱ្យចូលមកធ្វើការរួចហើយ មុនពេលចេញប្រកាសនេះ តែនៅមិនទាន់បានធ្វើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ត្រូវរៀបចំបែបបទធ្វើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ឱ្យបានមុនថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២។ បើនៅមិនទាន់មានកិច្ចសន្យាការងារទេ និយោជក និងសាមីជនបរទេស ក៏ត្រូវចុះកិច្ចសន្យាការងារនៅពេលជាមួយគ្នានេះដែរ។

ប្រការ៨: ម្ចាស់សហគ្រាសគ្រឹះស្ថាន ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ជាលាយលក្ខណ៍អក្សរ ស្តីពីការទទួលជនបរទេសឱ្យចូលធ្វើការ នៅពេលចុះកិច្ចសន្យាការងារ ឬបញ្ឈប់ជនបរទេសពីការងារ នៅពេលបញ្ចប់កិច្ចសន្យាការងារ ឬនៅពេលផ្តាច់កិច្ចសន្យាការងារ។ សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកនេះ ត្រូវបញ្ជូនទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចុះបញ្ជិកា ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានទទួលឱ្យធ្វើការ ឬបញ្ឈប់ពីការងារ។ ចំពោះអ្នកនៅរាជធានីភ្នំពេញ សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ត្រូវបញ្ជូនទៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។ ចំពោះអ្នកនៅខេត្តក្រុង សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកនេះ ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៃខេត្តក្រុងនីមួយៗ។

ប្រការ៩ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្តក្រុង

" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "

-សមាគមនិយោជក
-សហព័ន្ធសហជីព

" ដើម្បីជ្រាប "

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ